# Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

## របាយការណ៍ថ្មី អំពាវនាវឲ្យចាត់វិធានការ គាំពារផ្លូវទឹកសំខាន់សម្រាប់អាស៊ីអាគ្នេយ៍

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០២២** – សព្វថ្ងៃនេះ ដោយសារទន្លេមេគង្គដែលទ្រទ្រង់អាយុជីវិតប្រជាជន បានរងផលប៉ះពាល់ខ្លាំងពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ របាយការណ៍ថ្មីមួយ អំពាវនាវឲ្យមាន “ការទូតទឹក” ជាបន្ទាន់ ដើម្បីគាំពារទន្លេធំជាងគេបំផុតរបស់អាស៊ីអាគ្នេយ៍ និងលើកកម្ពស់ការអភិវឌ្ឍន៍ដោយចីរភាពសម្រាប់ប្រជាជនរាប់លាននាក់ នៅទូទាំងតំបន់នេះ។

នៅថ្ងៃនេះ គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) រួមមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម បានចេញផ្សាយនូវ “របាយការណ៍សមិទ្ធិផល” របស់ខ្លួន សម្រាប់ផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០១៦-២០២០។ របាយការណ៍នេះ គូសបញ្ជាក់ពីព្រឹត្តិការណ៍ថ្មីៗ ក្នុងកិច្ចសហប្រតិបត្តិការទន្លេមេគង្គ ព្រោះថាវាបានរំលេចបង្ហាញពីសមិទ្ធិផលធំៗ វិធានការដែលបានអនុវត្ត និងសូចនាករសំខាន់ៗ ដែលជួយលើកកម្ពស់ការយល់ដឹងក្នុងតំបន់ទាំងមូលពីរបៀបដែលការអភិវឌ្ឍន៍ និងទឹកជំនន់ និងគ្រោះរាំងស្ងួតដែលកាន់តែធ្ងន់ធ្ងរ ជះឥទ្ធិពលលើអាងទន្លេមេគង្គក្រោម ទាំងវិជ្ជមាន និងអវិជ្ជមាន។

សកម្មភាពទាំងនេះ បានជំរុញប្រទេសជាសមាជិកឲ្យចាត់វិធានការបែបសម្របសម្រួល និងមិនធ្លាប់មានពីមុនមក រួមទាំងប្រតិបត្តិការជាមួយនឹងប្រទេសនៅផ្នែកខាងលើទន្លេទាំងពីរ គឺប្រទេសចិន និងមីយ៉ាន់ម៉ា។ របាយការណ៍កម្រាស់ ១៧៤ ទំព័រ ក៏មានគោលបំណងបោះពុម្ពផ្សាយនូវមេរៀនបទពិសោធន៍ជាសាធារណៈផងដែរ។ ក្នុងចំណោមបទពិសោធន៍ ដែលបច្ចុប្បន្ននេះ ត្រូវបានដាក់ឲ្យប្រើប្រាស់នៅក្នុងផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០២១-២០២៥ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ឆ្នាំ២០២១-២០៣០ របាយការណ៍បានលើកជាអនុសាសន៍ថា ទិន្នន័យទាន់ពេលវេលា និងចំណេះដឹងហ្មត់ចត់បែបវិទ្យាសាស្ត្រ គួរតែជំរុញអ្នករៀបចំផែនការ និងអ្នកតាក់តែងគោលនយោបាយ ក្នុងការសម្រេចចិត្ត និងការអនុវត្តរបស់គេ។

លោក ប្រាវិត វង្សស្វូវុន (Prawit Wongsuwon) ឧបនាយករដ្ឋមន្ត្រីថៃ និងជាប្រធានក្រុមប្រឹក្សា MRC ឆ្នាំ២០២១ មានប្រសាសន៍ថា សព្វថ្ងៃនេះ យើងត្រូវធ្វើការបន្ថែមទៀត ដើម្បីអនុវត្តយន្តការ និងគ្រប់គ្រងធនធានទឹកនានា។

លោក វង្សស្វូវុន ដែលជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គថៃ ថ្លែងថា “នៅក្នុងអាងទន្លេមេគង្គក្រោម ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បង្ហាញនូវផលវិបាកយ៉ាងខ្លាំងសម្រាប់សុខមាលភាពសង្គម និងសេដ្ឋកិច្ចរបស់យើង ដែលវាតំណាងឲ្យបញ្ហាប្រឈមកំពុងកើតឡើងមួយសម្រាប់អ្នកតាក់តែងគោលនយោបាយ។ ការទូតទឹក កាន់តែមានសារៈសំខាន់ខ្លាំងឡើងក្នុងតំបន់របស់យើង ជាពិសេសទាក់ទិននឹងកំណើននៃចំនួនគម្រោងទំនប់វារីអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធទឹកដទៃទៀត ព្រមទាំងសកម្មភាពអភិវឌ្ឍន៍នានា”។

ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ MRC បានកែសម្រួលក្របខណ្ឌសូចនាករ របស់ខ្លួនសម្រាប់វិស័យទាំងប្រាំក្នុងការគ្រប់គ្រងអាងទន្លេ នោះគឺបរិដ្ឋាន សង្គម សេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងកិច្ចសហប្រតិបត្តិការ។ រួមជាមួយគ្នា សូចនាករទាំងនេះ បង្កើតបាននូវទិដ្ឋភាពកាន់តែពេញលេញស្ដីពីស្ថានភាព និងនិន្នាការផ្សេងៗ សម្រាប់ផលប៉ះពាល់នៃការអភិវឌ្ឍន៍ និងកាលានុវត្តនានា។

របាយការណ៍នេះ បានដកស្រង់ឧទាហរណ៍ជាក់ស្ដែងពីមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតប្រចាំតំបន់របស់ខ្លួន ដែលកាលពីឆ្នាំ២០១៧ វាត្រូវបានពង្រីកដោយដាក់បញ្ចូលនូវការព្យាករណ៍ពីគ្រោះរាំងស្ងួត។ ចាប់តាំងពីពេលនោះមក សមត្ថភាពព្យាករណ៍នេះ បានជួយសង្គ្រោះអាយុជីវិត និងទ្រព្យសម្បត្តិប្រជាជនជាច្រើនដែលរស់នៅតាមអាងទន្លេ។ អ្វីដែលគួរឲ្យកត់សម្គាល់ជាពិសេសនោះគឺថា ការព្យាករណ៍ដែលបានកែលម្អនេះ គឺជាផលិតផលនៃទំនាក់ទំនងតំបន់កាន់តែស៊ីជម្រៅ ជាពិសេសជាមួយនឹងទីក្រុងប៉េកាំង។ នេះគឺជាលើកដំបូងបំផុត ដែលប្រទេសចិន យល់ព្រមចែករំលែកទិន្នន័យជលសាស្ត្ររដូវប្រាំងរបស់គេ។

បណ្ឌិត អាន ពេជ្រហត្ថដា ដែលជានាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC នាពេលនោះ លើកឡើងពីភាពជាដៃគូសំខាន់ៗផ្សេងទៀតនៅក្នុងបុព្វកថានៃរបាយការណ៍នេះ ថា “យើងបានធានាភាពជាដៃគូជាមួយនឹងមជ្ឈមណ្ឌលទឹកស្ដីពីកិច្ចសហប្រតិបត្តិការឡានឆាងមេគង្គ និងធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូរបស់យើងជាមួយនឹងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍។ កិច្ចសហប្រតិបត្តិការបែបនេះ បានផ្ដល់ជាប្រយោជន៍រួចមកហើយ។ កាលពីឆ្នាំមុន MRC និងអាស៊ាន បានរៀបចំសម្ភោធ “កិច្ចសន្ទនាស្ដីពីសន្តិសុខទឹក” ដើម្បីជំរុញឲ្យមានដំណោះស្រាយបែបនវានុវត្តន៍ ចំពោះបញ្ហាប្រឈមដែលកើតមានសម្រាប់សន្តិសុខទឹក”។

ជាការពិតណាស់ បច្ចុប្បន្ននេះ ប្រទេសតាមដងទន្លេមេគង្គ ជាអ្នកដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់ MRC យ៉ាងពេញលេញ។ មុនឆ្នាំ២០១៦ នាយកប្រតិបត្តិបរទេស គឺជាអ្នកដឹកនាំ ដោយមានបុគ្គលិកអន្តរជាតិជាច្រើននៅឯលេខាធិការដ្ឋាន ប៉ុន្តែនៅឆ្នាំ២០១៦ MRC បានចាត់តាំងនាយកប្រតិបត្តិដំបូងដែលមកពីប្រទេសជាសមាជិក នោះគឺបណ្ឌិត ហ្វាម ទួនផាន់។ លើសពីនេះផងដែរ សញ្ញាមួយនៃកំណែទម្រង់ស្ថាប័នដ៏ជោគជ័យនោះគឺថា សព្វថ្ងៃនេះ ក្រុមការងារទាំងមូល ដែលបច្ចុប្បន្នដឹកនាំដោយបណ្ឌិត អានុល័ក ខិធិឃួន រួមមានមន្ត្រីជំនាញមកពីបណ្ដាលប្រទេសទាំងបួន។ នៅឯកិច្ចប្រជុំកំពូលលើកទីបី របស់ MRC នៅឆ្នាំ២០១៨ មិនត្រឹមតែនាយករដ្ឋមន្ត្រីនៃប្រទេសទាំងបួនទេ ដែលបានបញ្ជាក់សារជាថ្មីនូវអាណត្តិ និងបេសកកម្មដ៏ពិសេសរបស់ MRC ប្រទេសចិន និងមីយ៉ាន់ម៉ា ក៏បានធ្វើការប្ដេជ្ញាចិត្តលើកិច្ចសហប្រតិបត្តិការផងដែរ។

បើយើងមើលឆ្ពោះទៅអនាគត ការរំលេចមួយនៃផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥ គឺក្រុមមន្ត្រីជំនាញរួមផ្នែកអាងទន្លេ ដែលតំណាងឲ្យប្រទេសទាំង ៦ តាមដងទន្លេមេគង្គ។ ក្រុមនេះ រួមចំណែកផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស សម្រាប់ការរៀបចំផែនការបែបបុរេសកម្ម ប្រព័ន្ធតាមដាន និងព័ត៌មានរួម និងការសម្របសម្រួលប្រតិបត្តិការអាង។ ដោយផ្អែកលើការកសាងដោយមានការចូលរួម និងទំនាក់ទំនងពីភាគីពាក់ព័ន្ធតាមស្ថាប័ន និងជាប្រចាំក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ MRC បន្តលើកកម្ពស់នូវដំណើរការ

ប្រឹក្សាយោបល់ជាមុនដោយបើកចំហ និងប្រកបដោយបរិយាបន្ន ដែលផ្តល់លទ្ធភាពឲ្យសាធារណៈជនចូលរួមដោយបុរេសកម្ម។ អន្តរកម្មទាំងនេះ នាំឲ្យមានការប្រឹក្សាយោបល់យ៉ាងជោគជ័យសម្រាប់រោងចក្រវារីអគ្គិសនីថ្មីទាំងបី។

**កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោក មាស សុភក្រ្ត មន្រ្តីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែលៈ sopheak@mrcmekong.org
ទូរស័ព្ទដៃៈ +៨៥៦-២០-៧៧៧៧៩១៦៨

###